**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**ស្តីពីការបន្តព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និងក្រុមហ៊ុន ម៉េម៉ាអង្គរ**

កាលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៥ និង ០០នាទី មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន ក្រុមហ៊ុន **ម៉េម៉ាអង្គរ** មានអាសយដ្ឋានស្ថិតនៅ ភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

## សមាសភាពចូលរួមក្នុងអង្គប្រជុំមាន៖

| **ក. តំណាងភាគីនិយោជក** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក មាស ប៊ុនរ៉ុង | នាយកប្រតិបត្តិ | ០៦៩ ២៤៣ ៨៨៨ |
| លោក រ៉ូ រដ្ឋា | អនុប្រធានផ្នែកធនធានមនុស្ស | ០៦៩ ៤០៦ ៧៧៧ |

| **ខ. តំណាងភាគីកម្មករនិយោជិត** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក កេង ធារី | ប្រតិភូបុគ្គលិកពេញសិទ្ធិ | ០៦៩ ៤២៥ ៧៧៧ |
| លោក ស៊ឹម ស៊ីដេត | ប្រតិភូបុគ្គលិកជំនួយ | ០៦៩ ៤២៩ ៧៧៧ |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធទៅនឹង ការព្យួរកិច្ចសន្យាការងារឲ្យបានសមស្របតាម សេចក្តីណែនាំលេខ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីទាំងពីរបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតចំនួន៦៨នាក់ ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ដោយទទួលបាននូវប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ៤០ដុល្លា អា-មេរិក ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមទៅដល់កម្មករនិយោជិតក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺ COVID-19 ធ្វើឲ្យបាត់បង់ប្រាក់ចំណូលហើយបង្ខំចិត្តផ្អាកអាជីវកម្មមួយរយៈ។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១៦ និង ៣០នាទី រសៀល ថ្ងៃ ខែ ឆ្នាំដដែល ដោយមានការចុះហត្ថលេខា ព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម៖

**តំណាងភាគីនិយោជក**

ហត្ថលេខា/ស្នាមមេដៃ

**លោក មាស ប៊ុនរ៉ុង**

នាយកប្រតិបត្តិ

**លោក រ៉ូ វដ្ឋា**

អនុប្រធានផ្នែកធនធានមនុស្ស

**តំណាងភាគីកម្មករនិយោជិត**

ហត្ថលេខា/ស្នាមមេដៃ

**លោក កេង ធាវី**

ប្រតិភូបុគ្គលិកពេញសិទ្ធិ

**លោក ស៊ឹម ស៊ីដេត**

ប្រតិភូបុគ្គលិកជំនួយ